**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**

**<u>សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៨</u>**

**ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១**

**<u>សំណុំរឿងជំនុំជម្រះលេខ ១៣២</u>**

**ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣**

**<u>សាលក្រមកំបាំងមុខលេខ ៧៥ "ខ"/២១១</u>**

**ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣**

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តឧត្តរមានជ័យ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ពេលរសៀល ដោយមានសមាសភាពដូចតទៅ:

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ សៀម ណារី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ សៀម ណារី

### ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **ណារី** ភេទស្រី អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មុខរបរក្រុមប្រឹក្សាស្រុកបន្ទាយអំពិល ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្ថិតនៅភូ[redacted] ខេត្តឧត្តរមានជ័យ កាន់សាសនាព្រះពុទ្ធ ប្ដីឈ្មោះ [redacted] **គឹមសាន** (លែងលះ) មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] សៀម (រ) ម្ដាយឈ្មោះ [redacted] ជា (រ) កម្រិតវប្បធម៌ថ្នាក់ទី៩ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិចារ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**-បានឃើញ** ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ ០៩៦/២៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ លេខ ១៣១ ដចត/២៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ។

### <u>អង្គហេតុមានដូចតទៅ៖</u>

Scanned with CamScanner

កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ ឈ្មោះ [redacted] ណារី ភេទស្រី អាយុ៤៣ឆ្នាំ បានអះអាងតាំងខ្លួនស្គាល់អ្នកធំច្រើននៅខេត្តឧត្តរមានជ័យ រួចបានយកប្រាក់ពីជនរងគ្រោះឈ្មោះ [redacted] សុខម៉ាលី ភេទស្រី អាយុ៤១ឆ្នាំ ចំនួន ១៣,០០០$ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដើម្បីជាថ្នូររត់ការឱ្យកូនប្រុសរបស់ជនរងគ្រោះឈ្មោះ [redacted] វិសាល អាយុ១៨ឆ្នាំ បានប្រឡងជាប់ចូលក្របខណ្ឌមន្ត្រីនគរបាល។ រហូតដល់ពេលចេញលទ្ធផល គឺកូនប្រុសរបស់ជនរងគ្រោះ ឈ្មោះ [redacted] វិសាល អាយុ១៨ឆ្នាំ ពុំបានប្រឡងជាប់ចូលកបខណ្ឌមន្ត្រីនគរបាលនោះទេ ឃើញដូចនេះជនរងគ្រោះ ឈ្មោះ [redacted] សុខម៉ាលី បានទំនាក់ទំនងទៅឈ្មោះ [redacted] ណារី ដើម្បីសុំយកប្រាក់ចំនួន ១៣,០០០$ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក នោះវិញ តែត្រូវឈ្មោះ [redacted] ណារី បានគេចវេសមិនព្រមប្រគល់ប្រាក់ទៅឱ្យជនរងគ្រោះវិញនោះទេ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការខេត្តឧត្តរមានជ័យ

## យល់ឃើញថា៖

១.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ាលី ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយនៅចំពោះមុខតុលាការថា ឈ្មោះ [redacted] ណារី ជាក្រុមប្រឹក្សាស្រុកបន្ទាយអំពិល។ ដើមឡើយឈ្មោះ [redacted] ណារី គាត់បានខ្ចីលុយខ្លួនចំនួន ១៣,០០០ (មួយម៉ឺនបីពាន់) ដុល្លារ ប៉ុន្តែគាត់សុំសងលុយនាងខ្ញុំត្រឹមតែ១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ ខ្លួនក៏ព្រម ហើយឈ្មោះ [redacted] ណារី។ ឈ្មោះ [redacted] ណារី មិនទាន់សងលុយខ្លួនទេ។ តែគាត់សន្យាសងនៅថ្ងៃនេះតែម្តង បាញ់លុយចូលកុងរបស់ខ្លួន ហើយ ដោយបានបាញ់លុយចំនួណ២៥០០ (ពីរពាន់) ដុល្លារ នៅសល់ចំនួនលុយខ្លះទៀត គាត់សុំសងក្នុងរយៈពេល១៨ ខែក្រោយ ឥឡូវពួកខ្លួនបានចរចារគ្នាហើយ និងព្រមព្រៀងគ្នាដោះស្រាយគ្នានៅក្រៅតុលាការ។ ដើមឡើយឈ្មោះ [redacted] ណារី គាត់យកលុយដើម្បីរត់ការចូលក្របខណ្ឌរដ្ឋ ប៉ុន្តែបានប្រើរូបភាពជាក្តីខ្ចីលុយ។ ឈ្មោះ [redacted] ណារី គាត់ជាក្រុមប្រឹក្សាស្រុក គាត់ថា គាត់ស្គាល់អ្នកធំ គាត់អាចជួយរត់ការបាន។ ខ្លួនធ្លាប់បានទៅដល់សាលាស្រុកបានដឹងថា ឈ្មោះ [redacted] ណារី ជាក្រុមប្រឹក្សាស្រុកប្រាកដមែន ហើយពេលមានបញ្ហាខ្ញុំបានទៅជួបខាងសាលាស្រុក តែខាងសាលាស្រុកបានឱ្យខ្ញុំមកតុលាការ។ ថ្ងៃនេះខ្ញុំទទួលបានលុយ ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លារ ពីឈ្មោះ [redacted] ណារី នៅសល់ខ្លះទៀតចំនួន ៩៥០០ (ប្រាំបួនពាន់ប្រាំរយ) គាត់ថា ចាំសងលុយនោះមកខ្ញុំ១៨ខែក្រោយ។ គោលបំណងដែលខ្លួនប្តឹងឈ្មោះ [redacted] ណារី គឺដើម្បីឱ្យឈ្មោះ [redacted] ណារី ដែលគាត់បានខ្ចីខ្លួនសងលុយចំនួន ១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ អាមេរិក ដែលគាត់បានជំពាក់ខ្លួន។ ក្នុងចំនួនលុយ១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ អាមេរិក ពេលគាត់ខ្ចីខ្ញុំបានចុះកិច្ចសន្យាដោយមានកិច្ចសន្យាខ្ចីប្រាក់បានធ្វើជាមួយគ្នា។ ខ្លួនចង់ឱ្យគាត់សងលុយដែលគាត់បានជំពាក់ខ្លួន។

Scanned with CamScanner

២.តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណារី ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយនៅដំណាក់កាលអយ្យការថា ចំពោះពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សុខម៉ាលី ភេទស្រី អាយុ៤១ឆ្នាំ ដែលបានប្តឹងចោទ ប្រកាន់មកលើខ្លួននោះ គឺខ្លួនសូមបញ្ជាក់ថា ចំណុចខ្លះនៃអង្គហេតុ គឺពុំត្រឹមត្រូវនោះទេ។ ខ្លួនសូមជម្រាបជូនឯកឧត្តមព្រះរាជអាជ្ញា មេត្តាជ្រាបថា ខ្លួន និងដើមបណ្តឹងឈ្មោះ [redacted] សុខម៉ាលី ជាអ្នកស្គាល់រាប់អានគ្នាជាយូរមកហើយ។ ក្រោយមកឈ្មោះ [redacted] លីដា ភេទស្រី អាយុប្រហែល៦២ឆ្នាំ បានមកទំនាក់ទំនងខ្លួនឱ្យជួយកូនប្រុសរបស់ឈ្មោះ [redacted] សុខម៉ាលី ឈ្មោះ [redacted] វិសាល អាយុប្រហែល២៣ឆ្នាំ ដែលទើបប្រលងជាប់បាក់ឌុបបានចូលប្រលងក្របខណ្ឌមន្ត្រីនគរបាលជាតិ។ គាប់ជួនពេលនោះ គឺមានការប្រលងចូលក្របខណ្ឌមន្ត្រីនគរបាលជាតិនៅខេត្តឧត្តរមានជ័យ ដោយខ្លួនបានលើកជាយោបល់ថា បើចង់ឱ្យកូនប្រលងចូលរៀនមន្ត្រីនគរបាលជាតិ ចាំខ្ញុំសួរនាំអ្នកស្គាល់ឱ្យ។ ពេលនោះដើមបណ្តឹងបានប្រាប់ខ្ញុំថា គាត់មានលទ្ធភាពចំនួន១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក បើសិនជាខ្លួន អោយជួយឱ្យកូនបានប្រលងចូលរៀនជាមន្ត្រីនគរបាលជាតិ។ ការជជែកគ្នារវាងខ្ញុំ និងដើមបណ្តឹង គឺពុំមានលក្ខខណ្ឌអ្វីឡើយ។ ចំពោះលុយចំនួន១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក នោះពុំមែនជាលុយ ដើម្បីទៅសូកប៉ាន់គេឱ្យកូនគាត់បានប្រលងជាប់នោះទេ។ តែជាសាគុណដែលជួយគាត់បាន។ ម្យ៉ាងវិញទៀត លុយសាគុណនេះ គឺដើមបណ្តឹងស្ម័គ្រចិត្តប្រគល់ជូនខ្លួនមុនពេលចេញលទ្ធផល ដោយខ្លួនឯង ពុំមែនខ្លួនដាក់លក្ខខណ្ឌឱ្យគាត់នោះទេ។ ហើយខ្លួនសូមធ្វើការបញ្ជាក់ទៀតថា ប្រាក់សាគុណនេះគ្មានលក្ខខណ្ឌនោះទេ គឺឱ្យតែខ្លួនស្ម័គ្រចិត្តទោះបីជាប់មិនជាប់ក៏គាត់ឱ្យខ្លួន ដែរ។ ប៉ុន្តែដោយឃើញថា ដើមបណ្តឹងជាមនុស្សល្អហើយគាត់មានជីវភាពខ្វះខាត់ដែរ ណាមួយកូនរបស់គាត់មិនអាចចូលរៀនជា មន្ត្រីនគរបាលជាតិបានខ្លួនក៏ស្ម័គ្រចិត្តប្រគល់ប្រាក់សាគុណ ចំនួន១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ អាមេរិក នោះ ទៅឱ្យគាត់វិញទាំងអស់។ ដោយបច្ចុប្បន្នក្រុមគ្រួសារខ្លួនជួបវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ ទើបមិនអាចប្រគល់ជូនទៅដើម បណ្តឹងវិញភ្លាមបាន។ ខ្លួនសុំសន្យាថា នឹងប្រគល់ប្រាក់ចំនួន១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ អាមេរិកទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញនៅពេលខ្លួនលក់ផ្ទះរបស់ខ្លួនបាន ព្រោះថាសព្វថ្ងៃនេះ ខ្លួនកំពុងដាក់ប្រកាសលក់ជាសារធារណៈផងដែរ។ ខ្លួនសូមធ្វើការបញ្ជាក់បន្ថែមថា នៅក្នុងរឿងហេតុនេះមានការពាក់ព័ន្ធ គឺខ្លួនតែម្នាក់ប៉ុណ្ណោះ ហើយពុំមានការពាក់ព័ន្ធអ្នកផ្សេងឡើយ។ ចំពោះក្នុងរឿងហេតុនេះដែរ ខ្លួនសូមសំណូមពរ ស្នើសុំឱ្យឯកឧត្តមព្រះរាជអាជ្ញា មេត្តាទុកពេលមួយរយៈដើម្បីបានស្វែងរកប្រាក់មកប្រគល់ជូនដើមបណ្តឹងវិញ។

៣.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ង៉ុប ភេទប្រុស អាយុ៥២ឆ្នាំ បានឆ្លើយនៅដំណាក់កាលចៅអយ្យការថា រូបខ្លួនសូមជម្រាបជូនឯកឧត្តមព្រះរាជអាជ្ញា មេត្តាជ្រាបថា ខ្លួនមិនដែលមានទំនាក់ទំនងជាមួយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខម៉ាលី ភេទស្រី នោះទេ។ ហើយចំពោះរឿងហេតុដែលដើមបណ្តឹងគាត់បានប្តឹងនោះ ខ្លួនក៏បានមិនបានដឹងនោះដែរ។ កាលពីថ្ងៃទីមិនចាំ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ [redacted] សុណារី ភេទស្រី អាយុប្រហែល៤៣ឆ្នាំ បានមកជួបខ្លួន ដើម្បីមានភាពកក់ក្តៅក្នុងការប្រគល់ប្រាក់សាគុណ ដែលគាត់បានរត់ការឱ្យឈ្មោះ [redacted] វិសាល ភេទប្រុស ប្រលងចូលក្របខណ្ឌមន្ត្រីនគរបាលខេត្តឧត្តរមានជ័យ។ ហើយប្រាក់សាគុណដែលឈ្មោះ [redacted] សុណារី បានប្រគល់មកឱ្យខ្លួនមានចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ដែលជាសោហ៊ុយសាគុណក្នុងការប្រលងចូលក្របខណ្ឌ។ ហើយចំពោះប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ខ្លួនបានយកទៅប្រគល់ឱ្យឈ្មោះ [redacted] ភិន ភេទប្រុស អាយុប្រហែល៥៥ឆ្នាំ ដែលជាអធិការនគរបាលស្រុកបន្ទាយអំពិល ដើម្បីជា

Scanned with CamScanner

សាគុណ ក្នុងការប្រលងជាប់ក្របខណ្ឌមន្ត្រីនគរបាល។ ក្រោយមកនៅថ្ងៃទីមិនចាំ ដើមខែមេសា ឆ្នាំ២០២០ ដោយលទ្ធផលឈ្មោះ [redacted] វិសាល មិនបានប្រលងជាប់ជាមន្ត្រីនគរបាល។ រួចឈ្មោះ [redacted] ភិន គាត់ក៏យកប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក នោះមកឱ្យខ្លួនវិញ។ ហើយខ្លួនក៏យកទៅប្រគល់ឱ្យឈ្មោះ [redacted] សុណារី តែម្តង។ ក្រៅពីនេះខ្លួនពុំបានដឹងរឿងអ្វីនោះទេ។ ចំពោះក្នុងរឿងហេតុនេះដែរខ្លួនសូមស្នើសុំឱ្យឯកឧត្តមព្រះរាជអាជ្ញា មេត្តាជួយរកយុត្តិធម៌ និងសូមឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

៤.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ភិន ភេទប្រុស អាយុ៥៧ឆ្នាំ បានឆ្លើយនៅដំណាក់កាលអយ្យការថា រូបខ្លួនសូមជម្រាបជូន ឯកឧត្តមព្រះរាជអាជ្ញា មេត្តាជ្រាបថា ខ្លួន មិនដែលមានទំនាក់ទំនងជាមួយដើមបណ្តឹងឈ្មោះ [redacted] សុខម៉ាលី ភេទស្រី នោះទេ។ ហើយចំពោះរឿងហេតុដែលដើមបណ្តឹងគាត់បានប្តឹងនោះ ខ្លួនក៏បានមិនបានដឹងនោះដែរ។ កាលពីថ្ងៃទីខែមិនចាំ ឆ្នាំ២០១៩ ឈ្មោះ [redacted] សុណារី ភេទស្រី អាយុប្រហែល៤៣ឆ្នាំ បានមកជួបខ្លួន ដើម្បីបញ្ចូលឈ្មោះក្មួយប្រុសរបស់គាត់ (មិនចាំឈ្មោះ) ចូលជាសមាជិកក្នុងសៀវភៅគ្រួសាររបស់ឈ្មោះ [redacted] សុណារី ។ ក្រោយពីបានបានបញ្ចូលរួច ឈ្មោះ [redacted] ណារី គាត់បានមកទិញពាក្យសុំប្រលងចូលក្របខណ្ឌមន្ត្រីនគរបាលជាតិ នៅនឹងអធិការដ្ឋាននគរបាលស្រុកបន្ទាយអំពិល ដើម្បីឱ្យក្មួយប្រុសរបស់គាត់ (មិនស្គាល់ឈ្មោះ)។ ក្រោយមកពីឈ្មោះ [redacted] សុណារី បានដាក់ឱ្យក្មួយប្រុសរបស់គាត់រួចហើយឈ្មោះ [redacted] ង៉ុប គាត់ជាស្នងការរងនៃស្នងការនគរបាលខេត្តឧត្តរមានជ័យ បានទូរស័ព្ទមកខ្លួន ដោយសួរនាំពីឈ្មោះ [redacted] សុណារី ក្នុងការបញ្ចូលឈ្មោះក្នុងសៀវភៅគ្រួសាររបស់គាត់ និងការដាក់ពាក្យប្រលងចូលក្របខណ្ឌមន្ត្រីនគរបាលជាតិ ខ្លួនក៏ប្រាប់ទៅគាត់វិញថាបានធ្វើរួចរាល់អស់ហើយ។ ហើយឈ្មោះ [redacted] ង៉ុប គាត់បាននិយាយទៀត ថាចំពោះប្រាក់សាគុណដែលឪពុកម្តាយរបស់ក្មួយប្រុសរបស់ឈ្មោះ [redacted] សុណារី បានប្រគល់ទុកនៅនឹងគាត់រួចហើយ។ បន្ទាប់មកឈ្មោះ [redacted] ង៉ុប គាត់ក៏យកប្រាក់សាគុណ ចំនួន ៦,០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក នោះ មកប្រគល់ឱ្យខ្លួន ខ្លួនក៏ទទួល។ រហូតដល់ថ្ងៃចេញលទ្ធផលនៃការប្រលងក្មួយប្រុសរបស់ឈ្មោះ [redacted] សុណារី (មិនចាំឈ្មោះ) មិនបានប្រលងជាប់។ ខ្លួនក៏យកប្រាក់សាគុណចំនួន៦,០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិកនោះ ទៅប្រគល់ឱ្យឈ្មោះ [redacted] ង៉ុប វិញតែម្តង។ ក្រៅពីនេះខ្លួនពុំបានដឹងរឿងអ្វីនោះទេ។ ចំពោះក្នុងរឿងហេតុនេះដែរ ខ្លួនសូមស្នើសុំឱ្យ ឯកឧត្តមព្រះរាជអាជ្ញា មេត្តាជួយរកយុត្តិធម៌ និងសូមឱ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

៥.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនៅក្នុងសវនាការរួចមកឃើញថា ពាក់ព័ន្ធនឹងអង្គហេតុឆបោក ឃើញថានាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ណារី មិនបានចូលខ្លួនមកឆ្លើយនៅក្នុងសវនាការទេ ប៉ុន្តែផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមានទំនាក់ទំនងជាមួយឈ្មោះ [redacted] ណារី ទើបបានប្រើវិធីជាការខ្ចីប្រាក់ទៅវិញ ដូច្នេះ តំណាងអយ្យការយល់ឃើញថា ឈ្មោះ [redacted] ណារី គាត់បានធ្វើសកម្មភាពអះអាងប្រាប់ដើមបណ្តឹងថា ខ្លួនជាក្រុមប្រឹក្សាស្រុក ហើយខ្លួនស្គាល់អ្នកធំច្រើន ដែលអាចជួយកូនរបស់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យប្រឡងចូលក្រមខណ្ឌរដ្ឋបាន ដូច្នេះ នេះ គឺជាការជម្រុញនៃអំពើឆបោក ដោយសារតែការប្រែខ្លួន ឬក៏ជាការរំលោភអំណាចរបស់ខ្លួន ដោយសារបុគ្គលម្នាក់គាត់មានអំណាចរបស់គាត់ គាត់ជាក្រុមប្រឹក្សាស្រុក គាត់អាចរត់ការបាន ប៉ុន្តែគាត់បែរជារត់ការមិនបានសម្រេចនេះ ជាការរំលោភបំពានលើអំណាចរបស់ខ្លួន ហើយជាអំពើឆបោក។ ហេតុនេះ សូមលោកចៅក្រមជំនុំជម្រះពិចារណា

Scanned with CamScanner

សម្រេចកត់សម្គាល់អំពីបញ្ហានេះ ដូច្នេះតំណាងអយ្យការនៅតែរក្សា អង្គហេតុនៃអំពើឆបោក នេះដដែល និងស្នើសូមសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ណារី ភេទស្រី អាយុ៤៧ ឆ្នាំ ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិចារ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៦.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានមានសម្តី និងបានធ្វើសេចក្តីសន្និដ្ឋានបានថាខ្លួនសូមធ្វើការកត់សម្គាល់ខ្លីៗដូចតទៅ ពាក់ព័ន្ធនឹងសំណុំរឿងនេះផ្តើមចេញពីបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ាលី ទើបឈានដល់មានការចាត់ការតាមនីតិវិធីរហូតមកដល់ឥឡូវនេះ ដែលនៅក្នុងបណ្តឹង គឺមានភ្ជាប់ជាមួយនឹងភស្តុតាងកិច្ចសន្យាខ្ចីប្រាក់តាំងដំបូងរហូតមក។ ផ្អែកតាមការសួរដេញដោលរួចមក ទោះបីជាកូនក្តីរបស់ខ្លួនមិនចូលខ្លួនមកក្នុងសវនាការក៏ពិតមែន ប៉ុន្តែកូនក្តីរបស់ខ្លួនគាត់មានសិទ្ធិមានមេធាវីដើម្បីការពារសិទ្ធិជូនគាត់ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ខ្លួនអាចឆ្លើយការពារកូនក្តីរបស់ខ្លួនគ្រប់កាលៈទេសៈ ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់នៅក្នុងសវនាការថា គាត់ប្តឹងកូនក្តីរបស់ខ្លួន គឺដោយសារតែចង់ទាមទារប្រាក់ពីឈ្មោះ [redacted] ណារី ដោយសារគាត់មិនមែនជាអ្នកច្បាប់ កាលធ្វើសកម្មភាពនៅមិនទាន់មានមេធាវី គាត់អាចធ្វើសកម្មភាពខុសខ្លះ ទើបគាត់បានទាមទារប្រាក់ពីឈ្មោះ [redacted] ណារី តាមរយៈបណ្តឹងរបស់គាត់ ដោយផ្អែកតាមការសន្និដ្ឋានរបស់ខ្លួន គឺគាត់ចង់ធ្វើបែបណាដើម្បីឱ្យកូនក្តីរបស់ខ្លួនអាចសងប្រាក់ទៅគាត់វិញឱ្យបានលឿនបំផុត។ ចំណែកកូនក្តីរបស់ខ្លួនវិញ ក៏គាត់មានកំហុសខ្លះដែរ ដោយគាត់បានសន្យាម្តងទៅពីរដងថា នឹងប្រគល់លុយទៅឱ្យឈ្មោះ [redacted] សុម៉ាលី វិញ ប៉ុន្តែគាត់ធ្វើមិនបាន ដូចនេះ កំហុសដែលភាគីមិនអនុវត្តបំពេញកាតព្វកិច្ចជាការមិនអនុវត្តកិច្ចសន្យាមិនមែនជា បទល្មើសព្រហ្មទណ្ឌទេ។ ដូច្នេះ ខ្លួនស្នើសុំឱ្យលោកចៅក្រមជំនុំជម្រះស្នើសុំមេត្តាពិនិត្យពិចារណាឱ្យបានល្អិតល្អន់ទៅលើភស្តុតាងទៅលើការអះអាង ជាពិសេសចំពោះចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសូមសម្រេចឱ្យកូនក្តីរបស់ខ្លួនឈ្មោះ [redacted] ណារី រួចផុតពីបទចោទ។

៧.តាមអំណានចម្លើយរបស់ជនជាប់ចោទ, តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, តាមអំណាន និងក្រោយពីបានពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង រួចមក ឃើញថាកាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ ស្ថិតនៅចំណុចភូមិចារ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ពិតជាមានករណី **ឆបោក** ដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ណារី** ភេទស្រី អាយុ៤២ឆ្នាំ ប្រាកដមែន។

៨.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ណារី** ភេទស្រី អាយុ៤២ឆ្នាំ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **តាវ សុម៉ាលី** ភេទស្រី អាយុ៤២ឆ្នាំ គឺជាទំនាក់ទំនងខ្ចីប្រាក់ មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ជាក់ស្តែង នៅចំពោះមុខតុលាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុម៉ាលី** ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយថា គោលបំណងដែលខ្លួនប្តឹងឈ្មោះ [redacted] ណារី គឺដើម្បីឱ្យឈ្មោះ [redacted] ណារី ដែលគាត់បានខ្ចីខ្លួនសងលុយចំនួន ១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារ អាមេរិក ដែលគាត់បានជំពាក់ខ្លួន។

៩.មិនមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **ណារី** ភេទស្រី អាយុ៤២ឆ្នាំ ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិចារ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

១០.ជនជាប់ចោទឈ្មោះ [redacted] ណារី ភេទស្រី អាយុ៤២ឆ្នាំ គេចខ្លួន ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២២ ដ.ច.ខ/២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។ ដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរនៅតែមានអានុភាពដដែល រហូតមានដីកាបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួននេះ។ ដើម្បីចៀសវាងការបន្តស្វែងរកចាប់ខ្លួនបុគ្គលនេះ គប្បីតុលាការចេញដីកាបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២២ ដ.ច.ខ/២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តឧត្តរមានជ័យ។

**ហេតុដូច្នេះតុលាការ**

**វិនិច្ឆ័យសេចក្តី**

**១/-ឱ្យរួចផុតបទចោទលើឈ្មោះ** [redacted] ណារី ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណខាងលើ) ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិចារ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**២/.**បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២២ ដ.ច.ខ/២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តឧត្តរមានជ័យ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុម៉ាលី, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណារី។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ថ្ងៃពុធ ១០កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| [redacted] | [redacted] |

---

**បានឃើញ**

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១០កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner